**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**
លេខ...៤៧៧...ឃ.ឃ.ឥ../គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី..២០... ខែ..១៤... ឆ្នាំ២០.១២..

## សូមគោរពជូន

## ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
## និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

**តាមរយៈ៖** ឯកឧត្តមរដ្ឋលេខាធិការ និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប

**កម្មវត្ថុ៖** របាយការណ៍ស្តីពីលទ្ធផលនៃកិច្ចចរចាអំពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍រវាង កម្ពុជា-អាល្លឺម៉ង់ សម្រាប់ឆ្នាំ ២០១១-២០១២។

តបតាមខ្លឹមសារក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រីមេត្តាជ្រាបថា ខ្ញុំបាទត្រូវបានចាត់តាំងឲ្យចូលរួមជាសមាជិកគណៈប្រតិភូកម្ពុជា ដែលដឹកនាំដោយឯកឧត្តម **ឈៀង យ៉ាណារ៉ា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការ នៃគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ទៅបំពេញបេសកកម្មនៅសាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់ ដើម្បីធ្វើការចរចាអំពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ទ្វេភាគីជាមួយក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍អាល្លឺម៉ង់ (BMZ) សម្រាប់ឆ្នាំ ២០១១-២០១២ ដែលបានប្រព្រឹត្តទៅពីថ្ងៃទី ១១ ដល់ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១១។

### I. អំពីខ្លឹមសារជាទូទៅ និងបុរេលក្ខខ័ណ្ឌ នៃកិច្ចសហប្រតិបត្តិការ

ទោះបីជាកំពុងជួបប្រទះនូវការលំបាកយ៉ាងធ្ងន់ធ្ងរពីផលវិបាកនៃវិបត្តិសេដ្ឋកិច្ចពិភពលោក ជាពិសេសការទទួលខុសត្រូវយ៉ាងសំខាន់ក្នុងការដោះស្រាយវិបត្តិនៅក្នុងសហភាពអឺរ៉ុបក៏ដោយ ក៏អាល្លឺម៉ង់នៅតែបន្តតាំងចិត្តជួយគាំទ្រកម្ពុជាទាំងក្នុងកិច្ចសហប្រតិបត្តិការបច្ចេកទេស និងកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០១២ ដោយផ្តោតទៅលើវិស័យអាទិភាពសំខាន់ចំនួន ៣ ដូចខាងក្រោម៖

១- ផ្នែកសុខាភិបាល
២- ផ្នែកអភិវឌ្ឍជនបទ
៣- ផ្នែកដែលមានលក្ខណៈពហុវិស័យ៖ "អភិបាលកិច្ច"

ជាទូទៅ ដោយយល់ឃើញថាខ្លួននឹងត្រូវបញ្ចប់នូវជំនួយគាំទ្រផ្នែកកិច្ចសហប្រតិបត្តិការបច្ចេកទេសនាពេលខាងមុខឆាប់ៗនេះ អាស្រ័យហេតុនេះ ភាគីអាល្លឺម៉ង់បានដាក់លក្ខខ័ណ្ឌជាច្រើនភ្ជាប់ជាមួយនឹងជំនួយឆ្នាំ ២០១២ ខាងមុខនេះ ដោយកំណត់ឲ្យកម្ពុជាចាប់ផ្តើមរៀបចំជាគម្រោងផែនការថវិការដ្ឋដែលត្រូវបង្កើនជារៀងរាល់ឆ្នាំសម្រាប់ការចំណាយទៅលើវិស័យអាទិភាពទាំងបីខាងលើនេះ ដើម្បីធានាឲ្យមាននិរន្តរភាពនៃកិច្ចដំណើរការទៅអនាគត។

#### 1. អំពីផ្នែកសុខាភិបាល

មកទល់បច្ចុប្បន្ន អាល្លឺម៉ង់គាំទ្រវិស័យជាយុទ្ធសាស្ត្រចំនួន ៣ ក្នុងចំណោមវិស័យជាយុទ្ធសាស្ត្រទាំង ៥ នៃផែនការយុទ្ធសាស្ត្រសុខាភិបាលជាតិ (២០០៨-២០១៥) ពោលគឺ ការផ្តល់ហិរញ្ញប្បទានដល់ការថែរក្សាសុខភាព

ការផ្តល់សេវាសុខាភិបាល និងអភិបាលកិច្ចនៃប្រព័ន្ធសុខាភិបាល។ ជារួម អាល្លឺម៉ង់មានបំណងជំរុញឲ្យមានការពង្រឹងនូវប្រព័ន្ធជាតិនានាពាក់ព័ន្ធការគាំពារសុខមាលភាពសង្គមដែលមានលក្ខណៈជាអន្តរវិស័យ ដោយមិនមែនជាការទទួលខុសត្រូវរបស់ក្រសួងសុខាភិបាលតែឯកឯងនោះទេ។ ជាមួយគ្នានឹងវឌ្ឍនភាពនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ អាល្លឺម៉ង់នឹងគាំទ្រដល់កិច្ចដំណើរការផ្ទេរមុខងារសាធារណៈនានា ដែលពាក់ព័ន្ធផ្ទាល់នឹងការកាត់បន្ថយភាពក្រីក្រ និងជីវភាពរស់នៅ ទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រោមក្របខ័ណ្ឌថ្មីនៃអភិបាលកិច្ចប្រព័ន្ធសុខាភិបាល។

2. <u>អំពីផ្នែកអភិវឌ្ឍជនបទ</u>

ក. ផ្អែកលើលទ្ធផលនៃការអនុវត្តយ៉ាងជោគជ័យនៃកម្មវិធីហេដ្ឋារចនាសម្ព័ន្ធជនបទទី II (RIP II) នឹងដោយយល់ឃើញថា ការស្តារនីតិសម្បទាផ្លូវថ្នល់ ទីផ្សារ និងកីឡាដ្ឋានរបស់កម្មវិធីនេះ ពិតជាបានជួយពង្រឹងដល់ការអភិវឌ្ឍជនបទ អាល្លឺម៉ង់នៅតែបន្តគាំទ្រកម្មវិធីនេះសម្រាប់ដំណាក់កាលទី III ទៀត ប៉ុន្តែបានតម្រូវឲ្យក្រសួងអភិវឌ្ឍន៍ជនបទធានាថា ថវិការបស់ក្រសួងត្រូវចាប់ផ្តើមដាក់បញ្ចូលឲ្យបានច្រើនឡើងជារៀងរាល់ឆ្នាំសម្រាប់ការចំណាយទៅលើការជួសជុល និងថែរក្សា។

ខ. <u>ការគាំទ្រកំណែទម្រង់វិស័យដីធ្លី</u>៖ ដោយសារថវិកានៃគម្រោងអភិវឌ្ឍសេដ្ឋកិច្ចតំបន់ (RED) ដែលអនុវត្តដោយអាជ្ញាធរអប្សរាពុំអាចអនុវត្តបានពីព្រោះរាជរដ្ឋាភិបាលពុំបានដាក់នូវបដិភាគរបស់ខ្លួនដូចបានសន្យា អាស្រ័យហេតុនេះអាល្លឺម៉ង់បានសម្រេចផ្ទេរថវិកានេះមកគាំទ្រកំណែទម្រង់វិស័យដីធ្លី បើទោះបីជាមានជំទាស់ និងការទិះទានជាខ្លាំងពីសភា និងសង្គមស៊ីវិលរបស់អាល្លឺម៉ង់អំពីការអនុវត្តនូវគោលនយោបាយស្តីពីការតាំងទីលំនៅជាថ្មី និងសិទ្ធិមនុស្សរបស់កម្ពុជាក៏ដោយ។

ពាក់ព័ន្ធនឹងការបន្តគាំទ្រវិស័យសុរិយោដី និងការចុះបញ្ជីប្លង់ដីនេះ អាល្លឺម៉ង់យល់ថា វាជាកត្តាដ៏សំខាន់បំផុតដើម្បីធានាដល់ការអភិវឌ្ឍប្រទេសទៅអនាគត ដោយសារបទពិសោធន៍នៃពិភពលោក បានបង្ហាញឲ្យឃើញថា ការគ្រប់គ្រងបានយ៉ាងច្បាស់លាស់នូវដីធ្លីនឹងធានាឲ្យរដ្ឋរកបានប្រាក់ចំណូលយ៉ាងមហាសាល។ យ៉ាងណាមិញ ការបន្តគាំទ្រវិស័យនេះ ក៏មានកំណត់នូវសូចនាករ ឬលក្ខខ័ណ្ឌនៃការផ្តល់ហិរញ្ញប្បទានពីអាល្លឺម៉ង់យ៉ាងច្បាស់លាស់ ដោយទាមទារឲ្យកម្ពុជាធានាថារដ្ឋនឹងរៀបចំគម្រោងថវិការបស់ខ្លួនសម្រាប់ការចំណាយទៅលើកិច្ចសហប្រតិបត្តិការលើវិស័យនេះចាប់ពីឆ្នាំក្រោយទៅ និងមានការកើនឡើងសម្រាប់ឆ្នាំបន្តបន្ទាប់ទៀត។

3. <u>អំពីផ្នែកពហុវិស័យ៖ អភិបាលកិច្ច</u>

អាល្លឺម៉ង់យល់ព្រមបន្តគាំទ្រផ្នែកអភិបាលកិច្ចនេះលើ ៤ វិស័យ៖

- កំណែទម្រង់រដ្ឋបាលសាធារណៈ
- វិមជ្ឈការ និងវិសហមជ្ឈការ
- កម្មវិធីស្តីពីការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ (ID Poor)
- ការគាំទ្រដល់អាជ្ញាធរសវនកម្មជាតិ

ទោះបីយល់ព្រមបន្តគាំទ្រវិស័យទាំង ៤ នៃអភិបាលកិច្ចនេះក៏ដោយ តែភាគីអាល្លឺម៉ងនៅតែសម្តែងនូវការព្រួយបារម្ភអំពីកំណែទម្រង់លើប្រាក់បៀវត្សរបស់មន្ត្រីរាជការ ដោយខ្លួនមានគោលបំណងជំរុញឲ្យកម្ពុជាដាក់បញ្ចូលយន្តការនៃការចំណាយប្រតិបត្តិការអាទិភាព (POC) ទៅក្នុងថវិការបស់រដ្ឋជាបណ្តើរៗដើម្បីធានាបាននូវនិរន្តរភាព និងប្រសិទ្ធិភាពការងាររបស់មន្ត្រីរាជការក្នុងពេលដែល POC ត្រូវបានបញ្ចប់ការគាំទ្រពីដៃគូអភិវឌ្ឍពីខែ មិថុនា ឆ្នាំ ២០១២ តទៅ។

អាល្លឺម៉ង់បានវាយតម្លៃខ្ពស់ចំពោះវឌ្ឍនភាពនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដោយបានតាំងចិត្តបន្តផ្តល់ការគាំទ្រជាទ្វេភាគី និងតាមរយៈការរួមចំណែកជាថវិកាបន្ថែមទៀត ក្នុងនាមជាកម្មវិធីរបស់សហភាពអឺរ៉ុបសម្រាប់គាំទ្រកំណែទម្រង់នេះ។

**II. អំពីចំនួនថវិកាហិរញ្ញប្បទានសម្រាប់ឆ្នាំ ២០១១-២០១២**

យោងតាមលទ្ធផលនៃកិច្ចចរចានេះ ភាគីអាល្លឺម៉ង់បានឯកភាពផ្តល់ថវិកាសម្រាប់កិច្ចសហប្រតិបត្តិហិរញ្ញវត្ថុ និងកិច្ចសហប្រតិបត្តិការបច្ចេកទេសឆ្នាំ ២០១១-២០១២ សរុបចំនួន **៣១ លានអឺរ៉ូ**។

ក្នុងចំនួន ៣១ លានអឺរ៉ូ (ដោយមិនគិតបញ្ចូលនូវ ៥ លានអឺរ៉ូដែលកំពង់ស្នើសុំការសម្រេចពី BMZ សម្រាប់គាំទ្រការស្តារហេដ្ឋារចនាសម្ព័ន្ធដែលរងផលប៉ះពាល់ពីគ្រោះទឹកជំនន់) អាល្លឺម៉ង់ឯកភាពលើការបែងចែកថវិកាគាំទ្រនេះទៅតាមវិស័យអាទិភាពខាងលើដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ផ្នែកសុខាភិបាល | ៖ | ចំនួន ៦,២ លានអឺរ៉ូ |
| ២- ផ្នែកអភិវឌ្ឍជនបទ | ៖ | ចំនួន ១៧,៨ លានអឺរ៉ូ |
| ៣- ផ្នែកអភិបាលកិច្ច | ៖ | ចំនួន ៤,៣ លានអឺរ៉ូ |
| ៤- ការសិក្សា និងជំនាញការ | ៖ | ចំនួន ៣,៣ លានអឺរ៉ូ |

ពាក់ព័ន្ធនឹងផ្នែកអភិវឌ្ឍជនបទ អាល្លឺម៉ង់ផ្តោតជាសំខាន់លើការគាំទ្រដល់ការចុះបញ្ជីដីធ្លី និងការអភិវឌ្ឍគោលនយោបាយគ្រប់គ្រងដីធ្លី ដោយផ្តល់ថវិកាប្រមាណ ១៣,៨ លានអឺរ៉ូ។ ដោយឡែក ក្នុងផ្នែកអភិបាលកិច្ចដែលមានថវិការួមចំនួន ៤,៣ លានអឺរ៉ូ រួមមានការបែងចែកចំនួន ៣ លានអឺរ៉ូសម្រាប់គាំទ្រវិមជ្ឈការ និងវិសហមជ្ឈការ និងកំណែទម្រង់រដ្ឋបាលសាធារណៈ ចំនួន ១ លានអឺរ៉ូសម្រាប់គាំទ្រអាជ្ញាធរសវនកម្មជាតិ និង ៣០០.០០០ អឺរ៉ូសម្រាប់គាំទ្រ "កម្មវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ" របស់ក្រសួងផែនការ។

**III. សេចក្តីសន្និដ្ឋានជារួម**

ទោះបីជាទទួលបាននូវការតាំងចិត្តបន្តការគាំទ្រដល់កម្ពុជាសម្រាប់ឆ្នាំ ២០១១-២០១២ ប៉ុន្តែជាទូទៅរួមមាននូវការដាក់លក្ខខ័ណ្ឌជាច្រើនពីភាគីអាល្លឺម៉ង់ដើម្បីទទួលបាននូវហិរញ្ញប្បទានទាំងនេះ។ លក្ខខ័ណ្ឌសំខាន់ៗរួមមាន ការតម្រូវឲ្យកម្ពុជារៀបចំថវិកាជាតិរបស់ខ្លួនកាន់តែច្រើនឡើងក្នុងឆ្នាំជាបន្តបន្ទាប់ ដើម្បីធានាបាននូវភាពម្ចាស់ការក្នុងការអនុវត្តកិច្ចការអាទិភាពទាំងនេះ ក្នុងពេលដែលការគាំទ្រពីខាងក្រៅនឹងត្រូវកាត់បន្ថយជាបណ្តើរៗ ព្រមទាំងលក្ខខ័ណ្ឌនៃការគោរពសិទ្ធិរបស់ប្រជាពលរដ្ឋ រាប់បញ្ចូលទាំងប្រជាពលរដ្ឋដែលបានតាំងទីលំនៅមិនស្របច្បាប់នៅក្នុងការអនុវត្តគោលនយោបាយគ្រប់គ្រងដីធ្លី និងការចុះបញ្ជីដីធ្លី។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើនេះ សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រីមេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ង៉ាន់ ចំរើន

អគ្គនាយករងរដ្ឋបាលមូលដ្ឋាន